# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
## អភិបូជាអគ្គសញ្ញាលាបថ្ងាសនៅព្រះសហគមន៍សន្តហ្វ្រង់ស្វ័រសាវីយ៉េ
## ចំប៉ា ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៩

## យកព្រះជាម្ចាស់ជាមិត្តសម្លាញ់

**អត្ថបទទី១៖ ព្រះប្រាជ្ញាញាណ ១១,២៣-១២,២**

ព្រះអង្គស្រឡាញ់សត្វលោកទាំងអស់ មិនស្អប់ខ្ពើមសត្វលោកណាមួយ ដែលព្រះអង្គបានបង្កើតសោះឡើយ ប្រសិនបើព្រះអង្គស្អប់សត្វលោកណាមួយ ព្រះអង្គមិនបង្កើតសត្វនោះទេ។ ប្រាញ ១១,២៤

**អត្ថបទទី២៖ ថេស្សាឡូនិកទី២ ១,១១-២,២**

ព្រះនាមរបស់ព្រះយេស៊ូជាអម្ចាស់នៃយើង មានសិរីរុងរឿងនៅក្នុងបងប្អូន ហើយបងប្អូនក៏មានសិរីរុងរឿងក្នុងព្រះអង្គ តាមព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់នៃយើង និងព្រះអម្ចាស់យេស៊ូគ្រីស្តដែរ។ ២ថស ១,១២

**ដំណឹងល្អ៖ លូកា ១៩,១-១០**

បុត្រមនុស្សបានមក ដើម្បីស្វែងរក និងសង្គ្រោះមនុស្សដែលវិនាសបាត់បង់។ លក ១៩,១០

បងប្អូនជាទីស្រឡាញ់!

នៅក្នុងអត្ថបទទីមួយ ព្រះជាម្ចាស់បានជ្រើសរើសមនុស្ស១៤៤,០០០នាក់ ប៉ុន្តែមានមនុស្សជាច្រើនដែលចង់ចូលនៅក្នុងស្ថានបរមសុខ ដើម្បីមានជីវិតអស់កល្បជានិច្ចជាមួយព្រះជាម្ចាស់។ ថ្ងៃនេះ ជាពេលវេលាមួយដើម្បីគិតអំពីអនាគតរបស់យើងដែលជាគ្រីស្តបរិស័ទ យើងដឹងថាថ្ងៃណាមួយយើងនៅមុខទ្វារនៃស្ថានបរមសុខ យើងចង់ចូលប៉ុន្តែមិនដឹងថាយើងចូលបានឬអត់។ នៅលើផែនដីនេះ យើងធ្វើដូចម្តេចដើម្បីរៀបចំខ្លួនដែលអាចឲ្យយើងចូលនៅស្ថានបរមសុខជាមួយព្រះជាម្ចាស់បាន។ ថ្ងៃនេះ យើងគោរពសន្តបុគ្គលទាំងឡាយនៅក្នុងព្រះសហគមន៍ គោលដៅនៃជីវិតរបស់យើងគឺធ្វើដូចម្តេចដើម្បីចូលរួមនៅក្នុងក្រុមអ្នកដ៏វិសុទ្ធ ដើម្បីជាប់ជាមួយព្រះជាម្ចាស់។ សន្ត លូវីស មុនពេលគាត់ស្លាប់គាត់បាននិយាយទៅកូនគាត់ថា "**កូនអើយ! កុំព្រួយបារម្ភប៉ាជាមិត្តសម្លាញ់របស់ព្រះជាម្ចាស់**" ថ្ងៃនេះដើម្បីឲ្យយើងចូលនៅក្នុងភាពដ៏វិសុទ្ធ នៅក្នុងគោលដៅនៃជីវិតរបស់យើងធ្វើជាសន្តសន្តី ឲ្យយើងធ្វើដូចម្តេចដើម្បីចូលនៅក្នុងមិត្តភាពជាមួយព្រះជាម្ចាស់។

បងស្រីរបស់លោកឪពុកសុខណា គាត់បានស្លាប់ដោយសារដាច់សរសៃឈាមនៅក្នុងខួរក្បាល គាត់មានពិការភាពតាំងពីតូចមកម្ល៉េះ។ ផ្ទះគាត់នៅក្បែរព្រះវិហារ ខ្ញុំជឿថាគាត់បានបង្កើតទំនាក់ទំនងជាមួយព្រះជាម្ចាស់យ៉ាងពិសេស នៅថ្ងៃដែលគាត់ស្លាប់ខ្ញុំជឿថាគាត់ភ្ជាប់ជាមួយព្រះ

ជាម្ចាស់នៅក្នុងរបៀបពិសេស។ ទោះបីគាត់មិនមានឈ្មោះជាសន្តសន្តី ដែលយើងគោរពទូទាំងពិភពលោក ប៉ុន្តែគាត់មានឈ្មោះនៅក្នុងព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់។ ព្រះជាម្ចាស់បានទទួលស្វាគមន៍គាត់ ដោយសារអស់មួយជីវិតរបស់គាត់ គាត់បានបង្កើតទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយព្រះជាម្ចាស់ នៅក្នុងសេចក្តីស្រឡាញ់ នៅក្នុងការអធិដ្ឋាន នៅក្នុងការស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ គាត់មិនបានធ្វើអ្វីពិសេស ប៉ុន្តែនៅក្នុងជីវិតសាមញ្ញធម្មតាពីមួយថ្ងៃទៅមួយថ្ងៃរបស់គាត់ គាត់បានអធិដ្ឋាន ស្តាប់ព្រះបន្ទូល និងធ្វើការងារប្រចាំថ្ងៃរបស់គាត់ ធ្វើឲ្យគាត់បានភ្ជាប់ជាមួយព្រះហឫទ័យព្រះជាម្ចាស់នៅក្នុងមិត្តភាព។

ថ្ងៃនេះ ខ្ញុំអញ្ជើញបងប្អូនទាំង៨៨នាក់និងគ្រីស្តបរិស័ទយើងទាំងអស់ពិចារណា **តើខ្ញុំធ្វើដូចម្តេចដើម្បីទៅជាមិត្តសម្លាញ់របស់ព្រះជាម្ចាស់យ៉ាងជិតស្និទ្ធ?** យើងតែងចែករំលែកជាមួយមិត្តសម្លាញ់យើង ទាំងអំណរសប្បាយ ទាំងទុក្ខព្រួយ ទាំងអ្វីៗដែលមាននៅក្នុងដួងចិត្តរបស់យើង។ យើងធ្វើដូចម្តេចដើម្បីបង្កើតទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយព្រះយេស៊ូ ដូចយើងមានជាមួយមិត្តសម្លាញ់យើង យើងធ្វើដូចម្តេចដើម្បីយល់ថាព្រះយេស៊ូជាមិត្តសម្លាញ់របស់យើងម្នាក់ដែលយើងអាចនិយាយអ្វីៗទាំងអស់ទៅកាន់ព្រះអង្គ។ យើងត្រូវការភ្ញាក់ស្មារតីជានិច្ច ដើម្បីទៅជាមិត្តសម្លាញ់របស់ព្រះយេស៊ូ នៅក្នុងគ្រប់កាលៈទេសៈនៃជីវិតរបស់យើង។ ឲ្យយើងដាក់ចិត្តជាអ្នកក្រីក្រ កុំឲ្យយើងពោរពេញដោយអំនួត និងជាពិសេសឲ្យយើងទៅជាអ្នកបម្រើសុខសន្តិភាព។ យើងចង់បានសុខសន្តិភាព កុំឲ្យយើងបាក់បែកគ្នា កុំឲ្យយើងឈ្លោះគ្នា កុំឲ្យយើងបង្កើតរឿងដែលគ្មានប្រយោជន៍។ បន្តិចទៀត ប្រទេសយើងនិងរំលឹកដល់បុណ្យឯករាជ្យជាតិ ជាថ្ងៃដែលប្រទេសយើងបានទទួលឯករាជ្យពិតមែន អ្វីដែលសំខាន់ធ្វើដូចម្តេចដើម្បីថែរក្សាឯករាជ្យហ្នឹង នៅក្នុងរង្វង់មួយដែលជាប្រជារាស្ត្ររបស់ប្រទេសកម្ពុជា ប្រជារាស្ត្ររបស់ព្រះជាម្ចាស់។ នៅក្នុងសង្គមក្តី នៅក្នុងព្រះសហគមន៍ក្តី យើងត្រូវការអធិដ្ឋានដើម្បីឲ្យប្រទេសយើងការពារថែរក្សាសុខសន្តិភាព ឲ្យយើងចេះធ្វើដំណើរជាមួយគ្នាដើម្បីផលប្រយោជន៍រួម។ ធ្វើដូចម្តេច ដើម្បីឲ្យយើងទទួលស្គាល់បងប្អូនទាំងអស់ដែលរស់នៅលើទឹកដីប្រទេសកម្ពុជា មានសិទ្ធិដូចៗគ្នាអាចទៅសាលាបាន អាចទៅមន្ទីរពេទ្យបាន អាចបង្កើតសេចក្តីសុខនៅក្នុងគ្រួសារបាន អាចរកការងារធ្វើដើម្បីចិញ្ចឹមគ្រួសារបាន។

សម្រាប់យើងដែលជាព្រះសហគមន៍ យើងមិនគិតអំពីនយោបាយ ប៉ុន្តែយើងគិតអំពីសុភមង្គលសេចក្តីសុខសាន្តនៃប្រជារាស្ត្ររបស់យើង ឲ្យរស់នៅជាអង្គតែមួយ ជាផ្លូវតែមួយនៅក្នុងសុខដមរមនា ដើម្បីអនាគតកូនៗរបស់យើង។ ឲ្យយើងបម្រើសុខសន្តិភាព និងឲ្យយើងមានបេះដូងដូចព្រះបិតាដែលមានព្រះហឫទ័យមេត្តាករុណា ណែនាំឲ្យជីវិតរបស់យើងទៅជាមនុស្សម្នាក់

ដែលបង្ហាញធម៌មេត្តាករុណាដល់មនុស្សទាំងអស់។ ពេលយើងជោគជ័យ យើងដឹងថាយើងអាចទៅជាមនុស្សដ៏វិសុទ្ធ មនុស្សសុចរិតតាមរបៀបព្រះជាម្ចាស់។

ថ្ងៃនេះយើងអធិដ្ឋាន ដើម្បីឲ្យព្រះវិញ្ញាណដ៏វិសុទ្ធយាងមក ឲ្យយើងចេះទទួលខុសត្រូវយ៉ាងច្បាស់លាស់ ឲ្យយើងមានប្រាជ្ញាឈ្លាសវៃ ឲ្យយើងមានយោបល់ល្អ នេះជាអំណោយទានរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ ជាពិសេស ឲ្យយើងចេះគោរពគ្នាទៅវិញទៅមក ដោយគោរពព្រះជាម្ចាស់ជានិច្ច ព្រោះជាព្រះជាម្ចាស់ដែលប្រទានឲ្យយើងមានជីវិត ឲ្យយើងមានកម្លាំង ឲ្យយើងមានសេចក្តីសុខសាន្តនៅក្នុងខ្លួន។ ថ្ងៃនេះ យើងជឿថាយើងអាចមានឈ្មោះដើម្បីឡើងស្ថានបរមសុខ យើងមានបងប្អូន៨៨នាក់ដែលត្រៀមខ្លួនទទួលព្រះវិញ្ញាណដ៏វិសុទ្ធ។ យើងទាំងអស់គ្នាយើងដឹងថា យើងជាឪពុកម្តាយដែលបានយកចិត្តទុកដាក់នឹងអនាគតកូន យើងជាលោកតាលោកយាយដែលអប់រំកូនចៅឲ្យស្គាល់ព្រះយេស៊ូផង ឲ្យមានចំណេះដឹងផង ឲ្យមានសេចក្តីសុខនៅក្នុងជីវិតផង។ កូនៗត្រូវតែយកចិត្តទុកដាក់កុំឲ្យយើងទៅជាមនុស្សខ្ជិល កុំឲ្យយើងទៅជាមនុស្សអសកម្ម ឲ្យយើងពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធដើម្បីបង្កើតជីវិតយើងផ្ទាល់ ជីវិតនៃព្រះសហគមន៍របស់យើង និងបង្កើតសង្គមរបស់យើងឲ្យរកឃើញអនាគតដែលប្រកបដោយយុត្តិធម៌ និងអំណរសប្បាយមកពីព្រះជាម្ចាស់។ អាម៉ែន៕